**UNITED NATIONS**
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia
តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR

# លោកតំណាងពិសេស ភីធឺរ លយប្រែកតឺ អំពាវនាវសុំឱ្យលុបចោលសម្បទានដី របស់ក្រុមហ៊ុន WUZHISHAN L.S. GROUP នៅក្នុងខេត្តមណ្ឌលគីរី

៥ កក្កដា ២០០៥

លោកតំណាងពិសេស ស្នើសុំឱ្យរដ្ឋាភិបាលកម្ពុជាលុបកិច្ចព្រមព្រៀង ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ ២០០៤ ផ្តល់ដីរដ្ឋឱ្យក្រុមហ៊ុន WUZHISHAN L.S. GROUP ដើម្បីដាំដើមស្រល់នៅក្នុងខេត្តមណ្ឌលគីរី ជាហានដំបូងចំនួន ១០.០០០ ហិកតា ដោយបានសន្យាផ្តល់ដីចំនួន១៨៩.៩៩៩ ហិកតា[១] បន្ថែមទៀត ។ រដ្ឋាភិបាល និងក្រុមហ៊ុនមិនបានយកចិត្តទុកដាក់ដល់សុខមាលភាព វប្បធម៌ និងជីវភាពរស់នៅរបស់ជនជាតិដើមភាគតិចភ្នង ដែលមានចំនួនច្រើនជាងពាក់កណ្តាល នៃប្រជាពលរដ្ឋសរុបនៅក្នុងខេត្តនេះឡើយ ហើយថែមទាំងបានប្រព្រឹត្តរំលោភច្បាប់ និងសិទ្ធិមនុស្សទៀតផង ។

ដូចគ្នានឹងសម្បទានដីគោលដៅសេដ្ឋកិច្ចដទៃទៀតដែរ គឺមិនមានការវាយតំលៃផលប៉ះពាល់បរិស្ថាននិងសង្គមទេ ហើយក៏មិនមានការជូនដំណឹង និងការពិគ្រោះយោបល់ជាមួយអាជ្ញាធរ និងប្រជាពលរដ្ឋមូលដ្ឋានដែរ ។ គ្មានផែនទីជាក់លាក់ណាមួយបង្ហាញអំពីដីសម្បទាន ឬការដ្ឋាននានា ដែលក្រុមហ៊ុនកំពុងប្រតិបត្តិការឡើយ ។ គេមិនបានដឹងប្រាកដអំពីទំហំបច្ចុប្បន្ននៃដីសម្បទាននេះទេ ប៉ុន្តែជាទូទៅគេជឿថាមានទំហំ លើសពី ១០.០០០ ហិកតា ដែលច្បាប់ភូមិបាលកំណត់មិនឱ្យលើសពីនេះ ។

សម្បទានដីស្ថិតនៅតាមតំបន់វាលស្មៅនៃខ្ពង់រាប និងព្រៃក្រាស់ នៅតាមជ្រលងភ្នំ និងនៅអមសងខាងអូរភាគខាងត្បូងនៃខេត្តមណ្ឌលគីរី ។ នៅក្នុងខែកញ្ញា ឆ្នាំ២០០៤ ក្រុមហ៊ុនបានចាប់ផ្តើមបាញ់ថ្នាំគីមីយ៉ាងច្រើនសំលាប់ស្មៅ នៅលើតំបន់ខ្ពង់រាប បន្ទាប់មកបានដុតបំផ្លាញស្មៅទាំងនោះចោល ។ ពួកជនជាតិដើមភាគតិចភ្នង ចិញ្ចឹមសត្វពាហណៈរបស់ខ្លួនដោយអោយស៊ីស្មៅនៅតាមតំបន់ខ្ពង់រាបនោះ ។ នៅក្នុងប្រតិបត្តិការកាប់ឆ្ការព្រៃដើម្បីដាំដើមស្រល់ ក្រុមហ៊ុនបានបំផ្លិចបំផ្លាញផ្នូរបុព្វបុរស និងព្រៃតំណម ហើយមិនតែប៉ុណ្ណោះ ក្រុមហ៊ុនបានដណ្តើមយកស្រែ និងចំការរបស់ពួកគេទៀតផង ។ ទុក្ខកង្វល់របស់សហគមន៍ជនជាតិដើមភាគតិចភ្នង ដែលរងការប៉ះពាល់នេះ មិនត្រូវបានទទួលការយកចិត្តទុកដាក់ស្តាប់ឡើយ ហើយការព្រងើយកន្តើយបែបនេះនាំឱ្យពួកគេកាន់តែខឹងសម្បាយ៉ាងខ្លាំង ។ ពួកគេបានស្នើសុំឱ្យប្រគល់ដីមកឱ្យខ្លួនវិញ ហើយសុំឱ្យក្រុមហ៊ុនចាកចេញពីទីនោះ ។ ឥឡូវនេះ រដ្ឋាភិបាលបានចាប់ផ្តើមធ្វើការឆ្លើយតបហើយ ប៉ុន្តែនេះគ្រាន់តែជាវិធានការដោយអន្លើៗតែប៉ុណ្ណោះ ដែលរិតតែនាំមានភាពច្របូកច្របល់ខ្លាំងឡើងថែមទៀត ។

រដ្ឋាភិបាលមិនគួរណាសំរេចផ្តល់សម្បទានដីនេះ ឱ្យក្រុមហ៊ុន WUZHISHAN L.S. GROUP ទេ ។ ច្បាប់ភូមិបាលកំណត់ពីសិទ្ធិរបស់ជនជាតិដើមភាគតិច នូវសិទ្ធិកម្មសិទ្ធិលើដីសមូហភាព ។ ច្បាប់សំខាន់ៗសំរាប់អនុវត្តច្បាប់ភូមិបាល មិនទាន់បានអនុម័តនៅឡើយ ដែលក្នុងនោះរួមមានអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ អនុក្រឹត្យស្តីពីសម្បទានគោលដៅសេដ្ឋកិច្ច អនុក្រឹត្យស្តីពីការចេញប័ណ្ណកម្មសិទ្ធិដីសមូហភាព និងច្បាប់កំណត់លក្ខណៈវិនិច្ឆ័យអំពីឋានៈជនជាតិដើមភាគតិច ។

តំណាងពិសេសស្នើថា មិនត្រូវផ្តល់សម្បទានដីតទៅទៀត នៅក្នុងខេត្តមណ្ឌលគីរី ឬ ខេត្តដទៃទៀត នៅក្នុងប្រទេសកម្ពុជាទេ ដោយត្រូវរង់ចាំរហូតដល់មានការអនុម័តច្បាប់ចាំបាច់ នឹងចូលជាធរមានសិន ។ លោកតំណាងពិសេស សូមគូសបញ្ជាក់ជាថ្មីម្តងទៀត អំពីអនុសាសន៍ ដែលលោកបានធ្វើនៅក្នុងរបាយការណ៍របស់លោក កាលពីខែវិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីសម្បទានដីគោលដៅសេដ្ឋកិច្ច ផ្អែកលើទស្សនៈវិស័យខាងសិទ្ធិមនុស្ស ។

---

[១] សូមមើលរបាយការណ៍ ចេញផ្សាយកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៥ ស្តីពី ក្រុមហ៊ុន WUZHISHAN L.S. GROUP និងចំការដើមស្រល់ នៅក្នុងខេត្តមណ្ឌលគីរី ។

របាយការណ៍នេះ គឺជាឧបសម្ព័ន្ធ នៃរបាយការណ៍ស្តីពីសម្បទានដីគោលដៅសេដ្ឋកិច្ច ទិដ្ឋភាពខាងវិស័យសិទ្ធិមនុស្ស របស់លោកតំណាងពិសេស ក្នុងខែវិច្ឆិកា ឆ្នាំ២០០៤ ។

#10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cohchr@online.com.kh
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លេខ ១០ ផ្លូវលេខ ៣០២ សង្កាត់បឹងកេងកង ១ ខ័ណ្ឌចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: ៨៥៥-២៣ ៩៨៧ ៦៧១ / ៩៨៧ ៦៧២ / ៩៩៣ ៥៩០ / ៩៩៣ ៥៩១ / ឬ ២១៦ ៣៤២ ទូរសារ: ៨៥៥-២៣ ២១២ ៥៧៩ ឬ ២១៣ ៥៨៧